(27)19-01-2010 VSK

60/7

# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍
សំណុំរឿងព្រហ្មទណ្ឌ
លេខ: ២៧
ចុះថ្ងៃទី ១៩-០១-២០១០
សាលដីកា
លេខ: ៨២(ដ)
ចុះថ្ងៃទី ២៨-១០-២០១០

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាឧទ្ធរណ៍

បានបង្កើតឡើងតាមច្បាប់ ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំនុំជម្រះក្តីដែលប្រកាស អោយប្រើតាមក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ១៩៩៣ បានបើកសវនាការជាសាធារណៈនៅសាលសវនាការសាលាឧទ្ធរណ៍នា ថ្ងៃទី២១-១០-២០១០ ដោយមានសមាសភាពដូចខាងក្រោម៖

**ក្រុមប្រឹក្សាជំនុំជម្រះ**

- លោក [redacted] ជាប្រធាន
- លោក [redacted] ជាចៅក្រមប្រឹក្សា
- លោក [redacted] ជាចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

- ឯកឧត្តម [redacted]

**ក្រឡាបញ្ជីសវនាការ**

- លោក [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ នៃរឿងព្រហ្មទណ្ឌលេខ ២៧ ចុះថ្ងៃទី ១៩-០១-២០១០

រវាង:

- ជនជាប់ចោទ:

១- ឈ្មោះ [redacted] ការីម ភេទប្រុស អាយុ១៩ឆ្នាំ ជាតិខ្មែរ កើតនៅសង្កាត់ច្រាំងចំរេះទី១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ មានទីលំនៅសព្វថ្ងៃ[redacted] ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ របររកស៊ីជាងឈើ ឪពុកឈ្មោះ[redacted] (រ) ម្តាយឈ្មោះ [redacted] (រ) ទោសពីមុនគ្មាន ចាប់ខ្លួន ថ្ងៃទី ០១-១០-២០០៨ (ដើមបណ្តឹងឧទ្ធរណ៍) ។

២- ឈ្មោះ [redacted] រ៉សេត ភេទប្រុស អាយុ២៨ឆ្នាំ ជាតិខ្មែរ កើតនៅភូមិ៣ សង្កាត់ច្រាំងចំរេះ ខណ្ឌឫស្សីកែវ មានទីលំនៅសព្វថ្ងៃផ្ទះ[redacted] ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ មុខរបរមិនពិតប្រាកដ ឪពុកឈ្មោះ [redacted] ម្តាយឈ្មោះ [redacted] ទោសពីមុនគ្មាន ចាប់ខ្លួន ថ្ងៃទី ~~០១-១០-២០០៨~~ ២៥.០៩.០០៩ (ដើមបណ្តឹងឧទ្ធរណ៍) ។

៣- ឈ្មោះ [redacted] អារីហ្វីន ហៅ ពីន ភេទប្រុស អាយុ២៣ឆ្នាំ ជាតិខ្មែរ កើត និងទីលំនៅសព្វថ្ងៃផ្ទះ [redacted] សង្កាត់ច្រាំងចំរេះទី១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted]) ម្តាយឈ្មោះ[redacted] ទោសពីមុនគ្មាន ចាប់ខ្លួន ថ្ងៃទី ០១-១០-២០០៨ (ចុងបណ្តឹងឧទ្ធរណ៍) ។



Scanned by CamScanner

ត្រូវជាប់ចោទពីបទ ប្លន់ (លួចមានគ្នាច្រើន) ប្រព្រឹត្តនៅសង្កាត់ច្រាំងចំរេះទី១ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី ២៦-០៩-២០០៨ ដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ហូរសាន់ ភេទប្រុស អាយុ៤២ឆ្នាំ មានទីលំនៅផ្ទះលេខ ៣១៦ ផ្លូវលេខ៥ ក្រុមទី១ ភូមិទី២ សង្កាត់ច្រាំងចំរេះទី១ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ (ចុងបណ្តឹងឧទ្ធរណ៍) ។

- តាមបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ១៥-៩-២០០៩ របស់ឈ្មោះ [redacted] ការីម ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ១៥៦(ក្រ២) ចុះថ្ងៃទី ០១-៩-២០០៩ របស់សាលាដំបូងរាជធានីភ្នំពេញ មិនសុខចិត្ត គ្រង់ចំណុចនៃសេចក្តីសំរេចទាំងមូល ។

- តាមបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ៣០-៩-២០០៩ របស់ឈ្មោះ [redacted] រ៉សេត ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ១៥៦(ក្រ២) ចុះថ្ងៃទី ០១-៩-២០០៩ របស់សាលាដំបូងរាជធានីភ្នំពេញ មិនសុខចិត្ត គ្រង់ចំណុចនៃសេចក្តីសំរេចទាំងមូល ។

- តាមបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ០៤-៦-២០១០ របស់ឈ្មោះ [redacted] អារីហ្វីន ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ១៥៦(ក្រ២) ចុះថ្ងៃទី ០១-៩-២០០៩ របស់សាលាដំបូងរាជធានីភ្នំពេញ មិនសុខចិត្ត គ្រង់ចំណុចនៃសេចក្តីសំរេចទាំងមូល ។

**អង្គហេតុ**

តាមរបាយការណ៍ ចុះថ្ងៃទី ២៦-០៩-២០០៨ របស់ប៉ុស្តិ៍នគរបាលរដ្ឋបាលច្រាំងចំរេះទី១ ថា កាលពីថ្ងៃទី ២៦-០៩-២០០៨ នៅវេលាម៉ោង ២១ និង៤៥ នាទី នៅចំណុចផ្ទះលេខ ៣១៦ ផ្លូវលេខ៥ ក្រុមទី១ ភូមិទី២ សង្កាត់ច្រាំងចំរេះទី១ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ ជាដើមបណ្តឹងឈ្មោះ [redacted] ហូរសាន់ ទៅសូត្រធម៌នៅវិហារទុកប្រពន្ធ និងកូនសំរាកនៅផ្ទះដោយចាក់សោរមិនបានដកហូតកូនសោរ ពេលនោះមានមនុស្សមួយក្រុមមានឈ្មោះ [redacted] ការីម , ឈ្មោះ [redacted] រ៉សេត , ឈ្មោះ [redacted] អារីហ្វីន , ឈ្មោះ [redacted] រ៉ូ ហ្វាន , ឈ្មោះ [redacted] រ៉ូហ្សា និង ឈ្មោះ [redacted] ថេប បានលូកដៃតាមចន្លោះទ្វារ ចាក់សោរទ្វារដែលម្ចាស់ ភ្លេចដកកូនសោរទុកហើយចាក់ចូលក្នុងផ្ទះ បានលួចយកទូរស័ព្ទម៉ាកណូគាចំនួន ០១គ្រឿង និងដោះយកខ្សែកផ្លាកទីន ០១ខ្សែពីកូនដើមបណ្តឹងកំពុងដេកពេលនោះកូនដើមបណ្តឹងបានភ្ញាក់ដឹងខ្លួន ហើយស្គាល់ ជនត្រូវចោទម្នាក់ឈ្មោះ [redacted] ការីម ហើយបានប្រាប់ទៅដើមបណ្តឹងដែលជាឪពុក ។ លុះដល់ថ្ងៃទី ២៧- ០៩-២០០៨ ដើមបណ្តឹងបានចាប់ និងនាំឈ្មោះ [redacted] ការីម មកអោយសមត្ថកិច្ចតែម្តង ។

- តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] ការីម បានឆ្លើយថាៈ ខ្លួនពិតជាបានប្រព្រឹត្តដូចការចោទ ប្រកាន់មែនគឺ ខ្លួនបានយកខ្សែក និងទូរស័ព្ទគេ ខ្លួនបានចូលផ្ទះរបស់ឈ្មោះ [redacted] ហូរសាន់ ខ្លួនស្គាល់ម្ចាស់ផ្ទះច្បាស់ ខ្លួនចូលផ្ទះគេពេលអត់ចាក់សោរផ្ទះ ខ្លួនអង្គុយលេងមុខផ្ទះគេមានច្រើន ខ្លួនយកទ្រព្យសម្បត្តិគេហើយយកទៅលក់ដោយអោយឈ្មោះ [redacted] នង , ឈ្មោះ ក្លាម យកទៅលក់បាន២០ដុល្លា ខ្លួនយក៥ដុល្លាសល់ ប៉ុន្មានអោយគេទាំងអស់ បក្សពួកខ្លួន គឺអ្នកភូមិខ្លួន ប៉ុន្តែពួកវាមិនដឹងទេ ថាខ្លួនបានចូលទៅលួចរបស់គេ ។ ខ្លួនពុំបានគាស់សោរគេទេ ខ្លួនដោះខ្សែក ពេលគេដេកលក់ពុំបានគាស់ទ្វារគេទេ។



Scanned by CamScanner

- តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] រ័សេត បានឆ្លើយថាៈ សាលាដំបូងរាជធានីភ្នំពេញ បានជំនុំជម្រះរឿងក្ដីខ្លួននៅថ្ងៃទី០១-៩-២០០៩ ហើយផ្ដន្ទាទោសលើខ្លួនដាក់ពន្ធនាគារកំណត់ ៥ឆ្នាំ ខ្លួនពុំធ្លាប់ដែលទទួលដឹងពីការជំនុំជម្រះទេ ។ ចំពោះការសំរេចរបស់សាលាដំបូងរាជធានីភ្នំពេញដាក់ពន្ធនាគារលើរូបខ្លួនកំណត់៥ឆ្នាំ ខ្លួនមិនព្រមទទួលយកទេ ព្រោះខ្លួនពុំបានប្រព្រឹត្តអំពើប្លន់ដូចការចោទប្រកាន់ទេ ដោយខ្លួនសុំប្ដឹងឧទ្ធរណ៍ នឹងសាលក្រមលេខ ១៥៦ (ក្រ២) ចុះថ្ងៃទី ០១-៩-២០០៩ របស់សាលាដំបូងរាជធានីភ្នំពេញ ។

- តាមចម្លើយដើមបណ្ដឹងឈ្មោះ [redacted] ហុរសាន់ បានឆ្លើយថាៈ នៅថ្ងៃទី ២៦-០៩-២០០៨ ម៉ោង ម្ភៃមួយសែសិបនាទី ខ្លួនចេញទៅថ្វាយបង្គំព្រះវិហារ ចំណែកប្រពន្ធចេញនៅគូបលក់ឥវ៉ាន់មុខផ្ទះហើយកូនស្រី ខ្លួនពីនាក់ដេកក្នុងផ្ទះរួចទ្វារបិទរួចចាក់សោរតែមិនបានដកសោរទេ ស្រាប់តែឈ្មោះ [redacted] ការីម បានលូកដៃយកទូរស័ព្ទដៃ និងដោះយកខ្សែកពីកូនស្រីខ្លួនកំពុងដេកលក់ពេលកូនស្រីភ្ញាក់ទាន់ឃើញឈ្មោះ យ៉ា ការីម រត់មកថ្នល់គេចខ្លួនបាត់តែម្ដង ។

- បានឃើញសាលក្រមព្រហ្មទណ្ឌលេខ ១៥៦ (ក្រ២) ចុះថ្ងៃទី ០១-០៩-២០០៩ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចថាៈ

១- ក/ ផ្ដន្ទាទោសលើឈ្មោះ [redacted] ការីម ភេទប្រុស អាយុ១៩ឆ្នាំ ដាក់ពន្ធនាគារកំណត់៥ឆ្នាំ គិតពី ថ្ងៃឃុំខ្លួន ថ្ងៃទី០១-១០-២០០៨ ។

ខ/ ផ្ដន្ទាទោសលើឈ្មោះ [redacted] សេត ភេទប្រុស អាយុ២៥ឆ្នាំ , ឈ្មោះ [redacted] អារីហ៊ីន ហៅ ពីន ភេទប្រុស អាយុ២៧ឆ្នាំ , ឈ្មោះ [redacted] រ៉ូហ្សា ភេទប្រុស អាយុ២១ឆ្នាំ និងឈ្មោះ [redacted] ថេប ហៅ ក្ដាម ភេទប្រុស អាយុ២៧ឆ្នាំ ដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់០៥ឆ្នាំ គិតពីថ្ងៃចាប់ឃុំខ្លួនបាន ។

គ/ ផ្ដន្ទាទោសលើឈ្មោះ [redacted] រ៉ូហ្សា ហៅ យ៉ាន ភេទប្រុស អាយុ១៦ឆ្នាំ ដាក់ពន្ធនាគារកំណត់ ២ឆ្នាំ ៦ខែ គិតចាប់ពីថ្ងៃចាប់ឃុំខ្លួនបាន ។

ពីបទៈ ប្លន់ ប្រព្រឹត្តនៅសង្កាត់ច្រាំងចំរេះទី១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី ២៦-៩-២០០៨ ។ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងត្រូវផ្ដន្ទាទោស តាមមាត្រា០៦ នៃច្បាប់ស្ដីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ និងមាត្រា៦៨ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

២- ក/ បង្គាប់អោយចាប់ខ្លួនឈ្មោះ [redacted] សេត , ឈ្មោះ [redacted] អារីហ៊ីន ហៅ ពីន , ឈ្មោះ [redacted] រ៉ូហ្សា និង ឈ្មោះ [redacted] ថេប ហៅ ក្ដាម និងធ្វើការឃុំខ្លួនឈ្មោះទាំងនេះនៅពន្ធនាគារ (ម១) នៃក្រសួងមហាផ្ទៃ ដើម្បីអនុវត្តទោស ។

ខ/ បង្គាប់អោយចាប់ខ្លួនឈ្មោះ [redacted] រ៉ូហ្សាន ហៅ យ៉ាន និងធ្វើការឃុំខ្លួនឈ្មោះនេះនៅពន្ធនាគារ (ម២) នៃក្រសួងមហាផ្ទៃ ដើម្បីអនុវត្តទោស ។

តាមមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ។

៣- វត្ថុតាង គឺខ្សែកលោហៈធាតុពណ៌ទង់ដែងចំនួន០១ខ្សែ បន្ទោងរូបបេះដូងលោហៈធាតុពណ៌ទង់ ដែងចំនួន ០១ ប្រគល់អោយឈ្មោះ [redacted] ហុរសាន់ ជាម្ចាស់ដើមវិញ ។

តាមមាត្រា ៣៥៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ។

៤- សាលក្រមនេះជំនុំជម្រះ នៅថ្ងៃទី ០១-០៩-២០០៩ ប្រកាសជាសាធារណៈ នៅថ្ងៃទី ០៩-៩-២០០៩ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ការីម កំបាំងមុខជនជាប់ចោទឈ្មោះ [redacted]



Scanned by CamScanner

រ៉ីសេត , ឈ្មោះ [redacted] អារីហ្វីន , ឈ្មោះ [redacted] រ៉ូហ្សាន , ឈ្មោះ [redacted] ហ្វា , ឈ្មោះ [redacted] ថេប និងដើមបណ្តឹង ។

60/4

ទុកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

- បានឃើញ បណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ១៥-០៩-២០០៩ របស់ឈ្មោះ [redacted]ការីម ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ១៥៦(ក្រ២) ចុះថ្ងៃទី០១-៩-២០០៩ របស់សាលាដំបូងរាជធានីភ្នំពេញ មិនសុខចិត្ត ត្រង់ចំណុចនៃសេចក្តីសំរេចទាំងមូល ។

- បានឃើញ បណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ៣០-៩-២០០៩ របស់ឈ្មោះ [redacted] រ៉ីសេត ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ១៥៦(ក្រ២) ចុះថ្ងៃទី ០១-០៩-២០០៩ របស់សាលាដំបូងរាជធានីភ្នំពេញ មិនសុខចិត្ត ត្រង់ចំណុចនៃសេចក្តីសំរេចទាំងមូល ។

- បានឃើញ បណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី០៤-៦-២០១០ របស់ឈ្មោះ [redacted] អារីហ្វីន ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ១៥៦(ក្រ២) ចុះថ្ងៃទី ០១-០៩-២០០៩ របស់សាលាដំបូងរាជធានីភ្នំពេញ មិនសុខចិត្ត ត្រង់ចំណុចនៃសេចក្តីសំរេចទាំងមូល ។

- បានឃើញ របាយការណ៍រឿង ចុះថ្ងៃទី ០១-៣-២០១០ របស់ចៅក្រមរបាយការណ៍សាលាឧទ្ធរណ៍ ។

## ពេលសវនាការ

- ជនជាប់ចោទឈ្មោះ [redacted] អារីហ្វីន (ចូល)
- ជនជាប់ចោទឈ្មោះ [redacted] រ៉ីសេត (ចូល)
- ជនជាប់ចោទឈ្មោះ [redacted] ការីម (ចូល)
- លោក [redacted] សុផង់ មេធាវីការពារក្តីអោយជនជាប់ចោទ (ចូល)
- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ហ្សសាន់ (អវត្តមាន)

ប្រធានក្រុមប្រឹក្សាអានរបាយការណ៍រឿង

- ជនជាប់ចោទឈ្មោះ [redacted] ការីម បានឆ្លើយថា ខ្លួនមិនសុខចិត្តនេះ ព្រោះកាត់ទោសខ្លួនម្នាក់ឯង ដាក់០៥ឆ្នាំ ហើយរឿងនេះខ្លួនប្រព្រឹត្តតែម្នាក់ឯងទេ ខ្លួនប្រព្រឹត្តរួចហើយទៅលួចតែម្នាក់ខ្លួនទេ ពេលប្រព្រឹត្តរួចហើយទើបជួបជុំគ្នាគូកនផឹកស៊ីជាមួយគ្នា ខ្លួនអត់បានប្រាប់ថាការផឹកស៊ីនេះ គឺបានលុយពីការប្រព្រឹត្តល្មើសទេ ។ ពេលផឹកស៊ីអស់លុយតែប្រហែល ១៥$ ។ ពេលយកខ្សែកទៅលក់ គឺខ្លួនយកទៅលក់តែម្នាក់ឯង ។ មូលហេតុគេដឹង ព្រោះពេលខ្លួនមកយកខ្សែកបានពេលចេញមកវិញ គឺគេស្រែក ។ ពេលខ្លួនលក់ បានលុយទើបបបួលមិត្តភ័ក្រ្តទៅស៊ីផឹក ។ មូលហេតុពឹងគេអោយនាំទៅលក់របស់ ព្រោះពុំមានមធ្យោបាយ (អត់អីជិះ) ។

- ជនជាប់ចោទឈ្មោះ [redacted] រ៉ីសេត បានឆ្លើយថា ខ្លួនមិនបានចាំមើលផ្លូវទេ គឺខ្លួនអង្គុយលេង ។

- ជនជាប់ចោទឈ្មោះ [redacted] អារីហ្វីន បានឆ្លើយថា ពេលវាប្រព្រឹត្តល្មើស ខ្លួនអត់បានដឹងទេ ពេល ឈ្មោះ [redacted] ការីម ប្រព្រឹត្តរួចឈ្មោះ [redacted] ការីម បបួលខ្លួនទៅផឹកស៊ី ពេលកំពុងជិះម៉ូតូ ។ ខ្លួនអត់បានដឹងថា ឈ្មោះ [redacted] ការីម បានរបស់ពីណាមកទេ គឺវាពឹងពាក់ខ្លួនអោយវាទៅលក់ ពេលលក់បានវានាំខ្លួនទៅផឹកស៊ី ។



Scanned by CamScanner

តំណាងមហាអយ្យការសន្និដ្ឋានថា:

ទោះជាជនជាប់ចោទមិនសារភាពកំហុសក៏ដោយ ក៏មានភស្តុតាងដាក់បន្ទុកហើយ សុំឲ្យតម្កល់សាលក្រមថ្នាក់ក្រោមទុកជាបានការ ។

- លោក [redacted] សុផង់ មេធាវីតំណាងអោយជនជាប់ចោទសន្និដ្ឋានថា: កូនក្តីខ្លួនមិនបានប្រព្រឹត្តទេ គឺ [redacted] ការីម ថាប្រព្រឹត្តតែម្នាក់ឯង សុំអោយកូនក្តីខ្លួនរួចពីបទចោទ ។ ដោយឡែក [redacted] ការីម និង [redacted] រ៉ុសេត សុំបន្ធូរបន្ថយទោស ។

- ក្រោយពីបានស្តាប់អំណានរបាយការណ៍រឿង
- ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ
- ក្រោយពីបាន ពិនិត្យ ពិចារណា និងពិភាក្សាត្រឹមត្រូវហើយ

**សាលាឧទ្ធរណ៍យល់ឃើញថា:**

១- បណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ០៩-៩-២០០៩ របស់ជនជាប់ចោទឈ្មោះ [redacted] ការីម, បណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ០៣-៩-២០០៩ របស់ជនជាប់ចោទឈ្មោះ [redacted] រ៉ុសេត និងបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ០៨-៦-២០១០ របស់ជនជាប់ចោទឈ្មោះ [redacted] អារីហ្វីន ហៅ ពីន ធ្វើឡើងក្នុងកំណត់ច្បាប់ យោងមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌអាចជំនុំជម្រះបាន ។

២- តាមអង្គហេតុនៃរឿងក្តីនេះករណីមានចោរចូលផ្ទះជនរងគ្រោះ លួចយកទ្រព្យសម្បត្តិនៅម្តុំភូមិ ២ សង្កាត់ច្រាំងចំរេះទី១ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៦-៩-២០០៨ នោះសមត្ថកិច្ចនគរបាលឃាត់ខ្លួនឈ្មោះ [redacted] ការីម ដែលត្រូវបានសង្ស័យថា ជាជនដៃដល់ចូលក្នុងផ្ទះជនរងគ្រោះ លួចយកទ្រព្យមានទូរស័ព្ទដៃម៉ាកណូគា ០១គ្រឿង និងនោះយកខ្សែកប្លាទីនពីកូនជនរងគ្រោះ០១ខ្សែ ខណៈពេលដែលជនរងគ្រោះមិននៅផ្ទះ ។

៣- តាមចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ [redacted] ការីម ថាខ្លួនចូលទៅក្នុងផ្ទះជនរងគ្រោះ ធ្វើសកម្មភាពលួចយកទ្រព្យអ្នកដទៃតែម្នាក់ឯងទេ ចម្លើយនេះមានលក្ខណៈស៊ីចង្វាក់គ្នានឹងចំលើយកូនស្រីរបស់ជនរងគ្រោះថា បានឃើញច្បាស់ និងស្គាល់ថា ជាឈ្មោះ [redacted] ការីម ម្នាក់ប្រាកដមែន ប៉ុន្តែចម្លើយនៅសមត្ថកិច្ចដើមចោទបានបញ្ជាក់ថា ការចូលលួចនៅផ្ទះជនរងគ្រោះពិតមែន តែចូលធ្វើសកម្មភាពតែម្នាក់ឯងមែន តែខ្លួនមានបក្សពួក ០១ចំនួនទៀត នៅយាមផ្លូវដូចឈ្មោះ [redacted] រ៉ុសេត , [redacted] ថេប , រ៉ូហ្វា និងឈ្មោះ យ៉ាន ដោយឡែកឈ្មោះ [redacted] អារីហ្វីន ហៅ ពីន មិននៅកន្លែងកើតហេតុទេ ខ្លួនយករបស់គេបានហើយ តាមផ្លូវខ្លួនបានជួបឈ្មោះ [redacted] អារីហ្វីន កំពុងជិះម៉ូតូ ។ ចំនុចនេះសាលាឧទ្ធរណ៍ គប្បីលើកមកពិចារណា ។

៤- តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] អារីហ្វីន ហៅ ពីន បញ្ជាក់ថា ខ្លួនបានជួបឈ្មោះ [redacted] ការីម តាមផ្លូវដោយចៃដន្យក៏ជូនទៅលក់របស់ ហើយនិងបានចូលរួមស៊ីផឹកជាមួយពួកគេដែរ ចំណុចនេះ ទោះបី [redacted] អារីហ្វីន ពុំមានការពាក់ព័ន្ធក្នុងអំពើប្រព្រឹត្តរបស់ជនរងគ្រោះឈ្មោះ [redacted] ការីម ក៏ដោយ ក៏ឈ្មោះនេះបានដឹងថាជារបស់លួចគេ និងចូលរួមអាស្រ័យផល ពីបទល្មើសដែល



Scanned by CamScanner

ឈ្មោះ [redacted]ការីម បានប្រព្រឹត្តនេះបញ្ជាក់អោយឃើញថា ជាបទល្មើសទទួលផលចោរកម្មដែល ជនជាប់ចោទឈ្មោះ [redacted] អារី ហ៊ីន គប្បីទទួលខុសត្រូវតាមច្បាប់ជាធរមាន ។

៥- មានភស្តុតាងគ្រប់គ្រាន់បញ្ជាក់អំពីភាពមានពិរុទ្ធរបស់ជនជាប់ឈ្មោះ [redacted] ការីម និង [redacted] រ៉សេត ពីបទ ប្លន់ ប្រព្រឹត្តនៅភូមិ២ សង្កាត់ច្រាំងចំរេះទី១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៦-៩-២០០៨ បទល្មើសដែលមានចែងអោយផ្តន្ទាទោសតាមមាត្រា០៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

៦- មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] អារីហ៊ីន ហៅ ពីន ពីបទ ទទួលផលចោរកម្ម ប្រព្រឹត្តនៅភូមិ២ សង្កាត់ច្រាំងចំរេះ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី ២៦-៩-២០០៨ តាមមាត្រា ៥១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

៧- សាលក្រមព្រហ្មទណ្ឌលេខ ១៥៦ (ក្រ២) ចុះថ្ងៃទី ០១-០៩-២០០៩ របស់សាលាដំបូងរាជធានីភ្នំពេញ មានលក្ខណៈត្រឹមត្រូវតាមច្បាប់ហើយគួរតម្កល់ជាបានការ ។

៨- សាលព្រហ្មទណ្ឌលេខ ៥៦(ក្រ២) ចុះថ្ងៃទី ១១-០៥-២០១០ របស់សាលាដំបូងរាជធានីភ្នំពេញ មានលក្ខណៈត្រឹមត្រូវតាមច្បាប់ហើយគួរតម្កល់ លើកលែងតែចំនុចទណ្ឌកម្មលើជនជាប់ចោទ ឈ្មោះ [redacted] អារីហ៊ីន ហៅ ពីន គប្បីកែប្រែតាមការយល់ឃើញខាងលើ ។

## **<u>ហេតុដូច្នេះ</u>**

## **<u>វិនិច្ឆ័យសេចក្តី</u>**

១- ទទួលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ០៨-០៦-២០១០ របស់ជនជាប់ចោទឈ្មោះ [redacted] អារីហ៊ីន ហៅ ពីន ទុកជាត្រឹមត្រូវតាមច្បាប់ ។

- ទទួលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ០៩-០៩-២០០៩ របស់ជនជាប់ចោទឈ្មោះ [redacted] ការីម និងបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ០៣-០៩-២០០៩ របស់ជនជាប់ចោទឈ្មោះ [redacted] រ៉សេត ទុកជាត្រឹមត្រូវតាមទម្រង់ ច្បាប់តែបដិសេធទាស់គតិច្បាប់ ។

២- កែប្រែបទចោទប្រកាន់លើជនជាប់ចោទឈ្មោះ [redacted] អារីហ៊ីន ហៅ ពីន ពីបទ ប្លន់ មកជាបទ ទទួលផលចោរកម្ម វិញ ។

៣- តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ១៥៦ (ក្រ២) ចុះថ្ងៃទី០១-៩-២០០៩ នឹងសាលក្រមព្រហ្មទណ្ឌលេខ ៥៦ (ក្រ២) ចុះថ្ងៃទី ១១-០៥-២០១០ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការ លើកលែងតែទណ្ឌកម្មលើជនជាប់ចោទឈ្មោះ [redacted] អារីហ៊ីន ហៅ ពីន ត្រូវកែប្រែជា:

- ផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] អារីហ៊ីន ភេទប្រុស អាយុ២៣ឆ្នាំ ជាតិខ្មែរអ៊ីស្លាម ដាក់ពន្ធនាគារកំនត់ ០១ឆ្នាំ គិតចាប់ពីថ្ងៃទី២៨-០១-២០១០ ពីបទ ទទួលផលចោរកម្ម ប្រព្រឹត្តនៅភូមិ១ សង្កាត់ច្រាំងចំរេះ ខណ្ឌឫស្សីកែវ ក្រុងភ្នំពេញ កាលពីថ្ងៃទី២៦-៩-២០០៨ បទល្មើសដែលមានចែងអោយផ្តន្ទាទោសតាមមាត្រា ៥១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។ ក្រៅពីនេះរក្សាទុកនៅដដែល ។

៤- បន្តឃុំខ្លួនជនជាប់ចោទ ។

Scanned by CamScanner

៥- សាលដីកានេះជំនុំជម្រះជាសាធារណៈ នាថ្ងៃទី ២១-១០-២០១០ ចំពោះមុខជនជាប់ចោទ និងប្រកាសជាសាធារណៈ នៅថ្ងៃទី ២៨-១០-២០១០ កំបាំងមុខជនជាប់ចោទ តែចាត់ទុកជាចំពោះមុខ ។

- បើកផ្លូវប្ដឹងសាទុក្ខតាមកំណត់ច្បាប់ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សា |
|---|---|---|
| ហត្ថលេខា [redacted] | ហត្ថលេខា: [redacted] | ហត្ថលេខា: [redacted] |

---

បានឃើញ
ប្រធានក្រុមប្រឹក្សា
[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ភ្នំពេញ ថ្ងៃទី ២៥ ខែ [illegible] ឆ្នាំ ២០១៤
ក្រឡាបញ្ជី
[redacted]